## សាលារៀនបន្តការបញ្ជូនបន្តិចម្តងៗសម្រាប់សិស្សត្រឡប់ចូលរៀននៅក្នុងថ្នាក់វិញ

ក្រសួងអប់រំ ឡុងប៊ិច នឹងផ្តល់កម្មវិធីបង្ហាត់មេរៀនភាគច្រើនតាមរយៈ អនឡាញ រហូតដល់ ថ្ងៃទី28 ខែមករា ។ ប៉ុន្តែ សាលារៀន ក៏ចាប់ផ្តើមធ្វើបន្តិចម្តងៗផងដែរអំពីការបញ្ជូនសិស្សខ្លះត្រឡប់ចូលរៀននៅក្នុងថ្នាក់វិញ ។

ក្រសួងអប់រំ ឡុងប៊ិច ចាប់ផ្តើមឆមាសរដូវស្លឹកឈើជ្រុះ ដោយបើកថ្នាក់ ព្រីស្គូល និង ផ្តល់ជំនួយទទួលផ្ញើនៅតាមកន្លែងផ្សេងៗដាច់ដោយឡែកពីគ្នា ។ ការប្រឹងប្រែងជាបន្ថែមក្នុងរយៈពេលថ្មីៗនេះ គឺត្រូវបានសង្កត់មកលើសិស្ស ដែលមានសេចក្តីត្រូវការពិសេស ដោយផ្តើមធ្វើការស្ទង់វាស់មើល និង ប្រើមធ្យោបាយផ្សេងៗសម្រាប់ជួយបន្ទូរមកលើបញ្ហាច្រើនចំណែក ។

ដំណាក់ការជាបន្តបន្ទាប់ទៅសម្រាប់បញ្ជូនសិស្សត្រឡប់ចូលសាលារៀនវិញ គឺនឹងរាប់បញ្ចូលទាំងកម្មវិធីបង្ហាត់មេរៀននៅក្នុងថ្នាក់ផ្ទាល់កាន់តែច្រើនសម្រាប់ទទួលសិស្ស ដែលមានសេចក្តីត្រូវការពិសេស និង បន្ទាប់ទៅទៀត គឺមានគម្រោងផ្តើមបញ្ជូនសិស្សអាយុតូចៗត្រឡប់ចូលសាលារៀនវិញផងដែរ ។

លទ្ធផលទាក់ទងផ្នែកសុខភាពមកពី ឡូស អែនជេឡេស ខោនធី គឺនឹងណែនាំបង្ហាញអំពីការប្រើជំហាន ដែលក្រសួងអប់រំ LBUSD អាចបញ្ជូនសិស្សត្រឡប់ចូលសាលារៀនវិញបាន ។ នៅពេល អ៊ិលអេ ខោនធី ធ្លាក់ចុះទៅកាន់ជាន់ថ្នាក់ជាពណ៌ក្រហម (Red tier) ដែលមិនសូវជាកម្រិតតឹងរ៉ឹងពេក គឺការប្រើជំហានសម្រាប់បញ្ជូនសិស្សត្រឡប់ចូលសាលារៀនវិញនឹងមានភាពកាន់តែបង្កើន ។ លុះត្រាតែដល់ពេលនោះសិន គឺនៅពេលឥឡូវនេះ ក្រសួងអប់រំ LBUSD អាចបញ្ជូនសិស្សត្រឡប់ចូលសាលារៀនវិញបានត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះស្របតាមអ្វីដូចបានបង្ហាញមកពីការសុំលើកលែងពីច្បាប់ ហើយក្រសួងអប់រំ ឡុងប៊ិច នៅតែបន្តការស្វែងរកមើលអំពីអ្វីផ្សេងទៀត ដែលអាចធ្វើបានស្ថិតនៅក្រោមការជ្រើសរើសយកមួយនេះ ។

បុគ្គលិកនៅតែបន្តធ្វើការរែកញែកមើលអំពីលទ្ធផលទាក់ទងការផ្តល់ជំនួយបង្ហាត់មេរៀននៅក្នុងថ្នាក់ផ្ទាល់ ដែលសព្វថ្ងៃកំពុងចែកផ្តល់ក្នុងក្រសួងអប់រំ LBUSD ។ តាំងពីផ្តើមឆ្នាំសិក្សាមក ក្រសួងអប់រំ LBUSD បានផ្តល់កម្មវិធីទទួលផ្ញើក្មេង និង កម្មវិធី ព្រីស្គូល ទៅកាន់សិស្សប្រហែល 1,600 នាក់នៅតាម ហេដស្តាត Kid Clubs និង មណ្ឌលបណ្តុះបណ្តាលកុមារជាច្រើនកន្លែង ។ ក្នុងរយៈពេល ពីរ សប្តាហ៍កន្លងមក ក្រសួងអប់រំ ឡុងប៊ិច បានបិទសាលារៀនទាំងស្រុង (Dooley) និង សុំអោយសិស្សថ្នាក់ ព្រីស្គូល នៅឯមណ្ឌលបណ្តុះបណ្តាលកុមារ Grant Child Development Center សម្រាកនៅផ្ទះមួយរយៈពេល ដោយមូលហេតុថា ពួកគេប្រហែលជាបានទទួលការឆ្លងជម្ងឺកូវីដ ។ ដោយបានដកស្រង់ពីលទ្ធផលថ្មីៗនេះ និង ដោយមូលហេតុថា ចង់បញ្ជាក់អំពីភាពស្មោះត្រង់ គឺក្រសួងអប់រំ ឡុងប៊ិច កំពុងតែបង្កើតការតាំងបង្ហាញលទ្ធផលនៃជម្ងឺ កូវីដ (COVID dashboard) ដែលនឹងដាក់បញ្ចូលទៅក្នុងគេហទំព័រ ឡុងប៊ិច ក្នុងពេលឆាប់ៗខាងមុខនេះ ។

នៅពេលជាមួយគ្នានេះដែរ សាលារៀននៅតែបន្តបំពេញកិច្ចការជាច្រើនមធ្យោបាយ ។ បុគ្គលិកប្រចាំការិយាល័យសាលារៀនមានមុខងារចុះឈ្មោះសិស្សចូលរៀន និង ឃ្លាំមើលវត្តមានប្រចាំថ្ងៃ ជួយក្រុមគ្រួសារអំពីផ្នែកប្រើគ្រឿង បច្ចេកវិជ្ជា តាមសេចក្តីត្រូវការ និង បញ្ជូនក្រុមគ្រួសារអោយទៅទទួលយកជំនួយផ្សេងៗនៅតាមសហគមន៍ ។ អ្នកផ្តល់ឱវាទកំពុងធ្វើការ និង ផ្តល់ឱកាសសម្រាប់ជួបទៅកាន់សិស្ស និង ក្រុមគ្រួសារនៅក្នុងគ្រាដ៏សែនលំបាកនេះ ។

ខែតុលាក៏ជាពេលមួយដែរសម្រាប់ការរៀនបន្ត និង ការកែសម្រួលឡើងវិញសម្រាប់គ្រូបង្រៀន ដែលបានចំណាយពេលរៀនអំពីចំណេះថ្មីៗតាមរយៈកម្មវិធីហ្វឹកហ្វឺនផ្តល់ឡើងដោយក្រសួងអប់រំ ឡុងប៊ិច ។ កម្មវិធីហ្វឹកហ្វឺនមានរាប់បញ្ចូលទាំង ការប្រើពេលយ៉ាងប្រសប់សម្រាប់បង្ហាត់មេរៀន ការប្រើ Zoom អោយមានភាពសក្តិសិទ្ធិ ការរៀបចំ ហូមវើក តាមរយៈរៀនពីចម្ងាយ និង មធ្យោបាយកាន់តែច្រើនសម្រាប់ជួយអប់រំលើកទឹកចិត្តទៅកាន់សិស្សនៅពេលរៀន និង តាមសេចក្តីត្រូវការផ្សេងៗ ។

ក្រសួងអប់រំ ឡុងប៊ិច នឹងបន្តការកែសម្រួលផ្នែកបង្ហាត់មេរៀន ស្របតាមយោបល់បានទទួលមកវិញពីសិស្ស ក្រុមគ្រួសារ និង បុគ្គលិក ។